ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ
**STUDENTS' MOVEMENT FOR DEMOCRACY**

ផ្ទះលេខ៣៨ ផ្លូវ១៣៤ សង្កាត់ផ្សារដេប៉ូ២ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
#38, St.134, Phsar Depou II, Toul Kok, Phnom Penh, Cambodia.
Tel:(855-12)938 601 . Fax:(855-12)861515.
E-mail:012938601@mobitel.com.kh. Internet: www.smdcambodia.homepage.com

លេខ:..055/00...ច.ន.ប្រ

# ញត្តិ

## ថ្វាយព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

- ដោយយល់ឃើញថា សន្ធិសញ្ញា និងកិច្ចព្រមព្រៀងនៅឆ្នាំ១៩៧៩ ១៩៨២ ១៩៨៣ និង១៩៨៥ រវាងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីការកំណត់ជាថ្មីនូវគំនូសព្រំដែនដីគោក និងសមុទ្ររវាងកម្ពុជា និងវៀតណាមសុទ្ធតែបានធ្វើឡើងក្រោមឥទ្ធិពលនយោបាយ និងយោធារបស់វៀតណាម និងបានធ្វើអោយខូចខាតប្រយោជន៍ជាច្រើនដល់កម្ពុជា និងប្រជាពលរដ្ឋខ្មែរនៅខេត្តតាមព្រំដែននានា ។
- ដោយយល់ឃើញថា ព្រះរាជសារព្រះមហាក្សត្រ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០០ បានស្នើដល់ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី អោយពិនិត្យពិចារណាលើសំណើរបស់អ្នកស្នេហាជាតិ ដែលសុំអោយរាជរដ្ឋាភិបាលប្រកាសជាផ្លូវការនូវមោឃភាពនៃសន្ធិសញ្ញា និងកិច្ចព្រមព្រៀងទាំងនោះ ទៅរដ្ឋាភិបាលវៀតណាម។
- ដោយយល់ឃើញថា ចម្លើយរបស់សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល ថ្វាយព្រះមហាក្សត្រមានលក្ខណៈច្របូកច្របល់ ដោយសម្តេចបានទទួលស្គាល់ថា កិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីសស្តីពីកម្ពុជា ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ បានបញ្ជាក់នូវមោឃភាពនៃសន្ធិសញ្ញានិងកិច្ចព្រមព្រៀងខាងលើមែនហើយ ប៉ុន្តែដោយសម្តេចយល់ថាអ្នកតំណាងជាន់ខ្ពស់សព្វថ្ងៃនៃរដ្ឋាភិបាល និងសភាប្រទេសទាំងពីរកំពុងមានទំនាក់ទំនងល្អជាមួយគ្នា " រាជរដ្ឋាភិបាលពុំគួរចេញសេចក្តីប្រកាសជាផ្លូវការណ៍ និងជាចំហរស្តីពីការដាក់មោឃភាពនៃបណ្តាកិច្ចព្រមព្រៀង និងសន្ធិសញ្ញាទាំងនោះទេ ដោយទុកឱកាសជូនគណៈកម្មការចំរុះព្រំដែនកម្ពុជា-វៀតណាមបន្តធ្វើការចរចាគ្នា " តទៅទៀតចុះ។
- ដោយយល់ឃើញថា ក្នុងកំណត់ហេតុនៃការប្រជុំគ្នាលើកទី១ គឺថ្ងៃទី២២ ដល់២៧ ខែមិនា ឆ្នាំ១៩៩៩ គណៈកម្មការចំរុះកម្ពុជា-វៀតណាម បានយកសន្ធិសញ្ញា និងកិច្ចព្រមព្រៀង ១៩៨២-១៩៨៣ និង១៩៨៥ ទុកជាគោលការណ៍មូលដ្ឋានសំរាប់ដោះស្រាយបញ្ហាព្រំដែនរវាងប្រទេសទាំងពីរ ហើយនេះជាហេតុនាំអោយប៉ះពាល់យ៉ាងធំដល់បូរណភាពទឹកដីរបស់ប្រទេសកម្ពុជា ។

- ដោយយល់ឃើញថា រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា មាត្រាទី៥៥ បានបញ្ជាក់ថា " សន្ធិសញ្ញា និងកិច្ចព្រមព្រៀងទាំងឡាយណា ដែលមិនស្របនឹងឯករាជ្យ អធិបតេយ្យភាព បូរណភាពទឹកដី អព្យាក្រឹត្យភាព និងឯកភាពជាតិរបស់ប្រទេសកម្ពុជាត្រូវលុបចោល " ។

អង្គប្រជុំ " វេទិកាសាធារណៈ ស្ដីពីទីអវសាន នៃបូរណភាពទឹកដីខ្មែរ " បានធ្វើសេចក្ដីសំរេចចិត្ត នៅភ្នំពេញថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០០ ក្រាបបង្គំទូលថ្វាយ ព្រះករុណា ព្រះបាទសម្ដេច ព្រះនរោត្ដម សីហនុ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នូវសំនូមពរដូចតទៅ :

១. សូមព្រះអង្គទ្រង់ព្រះមេត្តាកុំឡាយព្រះហស្ថលេខា ឬ ប្រគល់សិទ្ធទៅប្រមុខរដ្ឋស្ដីទីចុះហត្ថលេខាជាមួយវៀតណាមលើឯកសារនានាដែលប៉ះពាល់ដល់បូរណភាពទឹកដីខ្មែរ ។

២. សូមព្រះអង្គទ្រង់ព្រះមេត្តាធ្វើអន្តរាគមន៏សុំអោយរាជរដ្ឋាភិបាលធ្វើជាលាយល័ក្ខអក្សរនូវសេចក្ដីប្រកាសមោឃភាពដល់បណ្ដាសន្ធិសញ្ញា និងកិច្ចព្រមព្រៀងឆ្នាំ១៩៧៩ ១៩៨២ ១៩៨៣ និង១៩៨៥ ដែលប៉ះពាល់ដល់បូរណភាពទឹកដីខ្មែរផ្ញើទៅជូនរដ្ឋាភិបាលវៀតណាម ។

៣. សូមព្រះអង្គព្រះមេត្តា ធ្វើអន្តរាគមន៏ សុំអោយរាជរដ្ឋាភិបាលបញ្ចប់កិច្ចចរចារ និងប្រកាសបដិសេធរាល់កិច្ចការ និងសេចក្ដីសំរេចរបស់គណៈកម្មការចំរុះកម្ពុជា-វៀតណាម ដើម្បីរក្សាសិទ្ធិដោះស្រាយ និងប្ដឹងទៅតាមផ្លូវច្បាប់ ។

៤. សូមព្រះអង្គទ្រង់ព្រះមេត្តា ជួយអោយមានការរៀបចំជាថ្មីនូវសមាសភាពគណៈកម្មការព្រំដែនជាតិពិសេសមួយ ដោយមានអ្នកច្បាប់ និងអ្នកបច្ចេកទេស ដែលមានសមត្ថភាពខ្ពង់ខ្ពស់ទាំងក្នុង និងទាំងក្រៅប្រទេស ហើយដែលជាអ្នកស្នេហាជាតិចូលរួម ដោយមិនប្រកាន់និន្នាការនយោបាយអ្វីទាំងអស់ ក្រោមព្រះរាជអធិបតីភាពព្រះមហាក្សត្រ ។

ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០០

ចម្លងថ្វាយ និងជូនៈ

- សម្ដេច ជា ស៊ីម ប្រធានព្រឹទ្ធសភា
- សម្ដេចក្រុមព្រះ នរោត្តម រណឫទ្ធិ ព្រះប្រធានរដ្ឋសភា
- សម្ដេច ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ក្រុមប្រឹក្សារដ្ឋធម្មនុញ្ញ
- ស្ថានទូតនានាប្រចាំកម្ពុជា
- សារពត៌មានជាតិ និងអន្តរជាតិ

តំណាងអង្គប្រជុំ

" វេទិកាសាធារណៈស្ដីពីទីអវសាននៃបូរណភាពទឹកដីខ្មែរ "

ឆូច ចិបុល

អនុប្រធានចលនានិស្សិត

ដើម្បីលទ្ធិប្រជាធិបតេយ្យ